**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍
លេខ៖ ០១៤/១៨ ក.ម.ក.ស.ទ.

# សេចក្តីណែនាំ
# ស្តីពី
# លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទូទាត់រវាងមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ ជាមួយនឹងគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ ដើម្បីផ្តល់សេវាទូរស័ព្ទចល័តនិងអ៊ិនធឺណិតល្បឿនលឿនចល័ត សម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨

អនុលោមតាមអនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍ ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (ក.ម.ក.ស.ទ.) សូមធ្វើការណែនាំអំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការទូទាត់រវាងមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (មូលនិធិ ក.ស.ទ.) ជាមួយនឹងគម្រោងអនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (កម្មវិធី ក.ស.ទ.) ដើម្បីផ្តល់សេវាទូរស័ព្ទចល័តនិងអ៊ិនធឺណិតល្បឿនលឿនចល័តសម្រាប់ឆ្នាំ២០១៧និងឆ្នាំ២០១៨ ដូចខាងក្រោម៖

## ១. ព័ត៌មានទូទៅ

### ១.១. គម្រោងនិងវិសាលភាពការងារដែលអនុញ្ញាតឱ្យមានការស្នើសុំទូទាត់

ប្រតិបត្តិករទូរគមនាគមន៍ អាចស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. នូវចំនួនទឹកប្រាក់យ៉ាងច្រើន ៥០% (ហាសិបភាគរយ) នៃវិភាគទានប្រចាំឆ្នាំដែលត្រូវបង់ចូលមូលនិធិ ក.ស.ទ. ដើម្បីផ្តល់សេវាទូរស័ព្ទចល័តនិងអ៊ិនធឺណិតល្បឿនលឿនចល័តសម្រាប់ឆ្នាំ២០១៧និងឆ្នាំ២០១៨ ក្នុងទម្រង់០៣(បី) ដូចខាងក្រោម៖

ក) ការស្នើសុំទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.

ខ) ការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៧ ឬកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨

គ) ការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៨ ឬកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៩។

គម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលអនុញ្ញាតឱ្យមានការស្នើសុំទូទាត់មាន ០២(ពីរ)ប្រភេទ ដូចខាងក្រោម៖

ក) ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (Passive Infrastructure) ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២ (ក)នៃសេចក្តីណែនាំនេះ។

ខ) ការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា (Active Infrastructure) ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២ (ក) នៃសេចក្តីណែនាំនេះ។

សេចក្តីលម្អិតនៃវិសាលភាពការងារ និងលក្ខខណ្ឌបច្ចេកទេសដែលពាក់ព័ន្ធនឹងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវាខាងលើ មានកំណត់ក្នុងឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៧ នៃសេចក្តីណែនាំនេះ។

### ១.២. ទីតាំងនៃគម្រោងដែលអនុញ្ញាតឱ្យមានការស្នើសុំទូទាត់

ប្រតិបត្តិករទូរគមនាគមន៍ អាចស្នើសុំទូទាត់នូវថវិកាដែលស្ថិតក្នុងគម្រោងចំណាយឬបាននិងកំពុងចំណាយចំពោះគម្រោងនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា ដើម្បីផ្តល់សេវាទូរស័ព្ទចល័តនិងអ៊ិនធឺណិតល្បឿនលឿនចល័តសម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ដែលស្ថិតនៅក្នុងតំបន់អាទិភាពដែលបានសម្រេចដោយ ក.ម.ក.ស.ទ. ឬតំបន់ផ្សេងទៀតដែលមានស្ថានភាពដូចខាងក្រោម៖

ក) តំបន់ជនបទដាច់ស្រយាល

ខ) តំបន់ខ្សែក្រវ៉ាត់ព្រំដែន

គ) តំបន់ចាំបាច់ផ្សេងទៀតដែលកំណត់ដោយ ក.ម.ក.ស.ទ.។

## ២. លក្ខខណ្ឌនិងបែបបទនៃការស្នើសុំទូទាត់

### ២.១. លក្ខខណ្ឌនៃការស្នើសុំទូទាត់

ប្រតិបត្តិករទូរគមនាគមន៍ ដែលមានគម្រោងស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**ក) លក្ខខណ្ឌទូទៅ ៖**

- ជាប្រតិបត្តិករទូរគមនាគមន៍ ដែលបានអនុវត្តពេញលេញក្នុងការបង់វិភាគទាន (២% នៃចំណូលដុល) ចូលមូលនិធិ ក.ស.ទ. សម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨
- ជាប្រតិបត្តិករទូរគមនាគមន៍ដែលពុំមានជាប់បំណុលដោយខកខានក្នុងបង់វិភាគទានចូលមូលនិធិ ក.ស.ទ.
- ជាប្រតិបត្តិករទូរគមនាគមន៍ដែលមានសក្តានុពលផ្នែកបច្ចេកទេស ផ្នែកហិរញ្ញវត្ថុ និងមានឆន្ទៈក្នុងការសម្រេចគម្រោងអនុវត្តកម្មវិធី ក.ស.ទ.
- ជាគម្រោងដែលពុំធ្លាប់ត្រូវបានអនុម័តរួច
- ជាគម្រោងដែលស្ថិតនៅក្នុងទីតាំង ហេដ្ឋារចនាសម្ព័ន្ធ បណ្តាញ និងប្រភេទសេវាទូរគមនាគមន៍ និងលក្ខណៈបច្ចេកទេសដែលបានកំណត់ដោយ ក.ម.ក.ស.ទ. និងសេចក្តីណែនាំនេះ។

**ខ) លក្ខខណ្ឌអាជ្ញាបណ្ណ ៖**

- ត្រូវមានអាជ្ញាបណ្ណក្នុងការសាងសង់និងផ្តល់សេវាប្រើប្រាស់បង្គោលអង់តែនទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ ឬ
- ត្រូវមានអាជ្ញាបណ្ណក្នុងការផ្តល់សេវា និងប្រតិបត្តិការបណ្តាញ និងសេវាទូរគមនាគមន៍ទូរស័ព្ទចល័តដោយប្រើប្រាស់សេវាជំនាន់ទី៣ (3G) ឬ
- ត្រូវមានអាជ្ញាបណ្ណប្រតិបត្តិការក្នុងការស្ថាបនានិងផ្តល់សេវាក្នុងវិស័យទូរគមនាគមន៍ ស្របតាម

ការកំណត់របស់ច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**គ) លក្ខខណ្ឌបច្ចេកទេស ៖**

សេចក្តីលម្អិតនៃលក្ខខណ្ឌបច្ចេកទេស មានកំណត់ក្នុងឧបសម្ព័ន្ធទី២ (ខ) នៃសេចក្តីណែនាំនេះ។

**២.២. បែបបទនៃការស្នើសុំទូទាត់**

ប្រតិបត្តិករទូរគមនាគមន៍ ដែលមានគម្រោងស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវដាក់ពាក្យស្នើសុំមកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. និងត្រូវភ្ជាប់ឯកសារ ដូចខាងក្រោម៖

**ក) ចំពោះការស្នើសុំទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.៖**

- ពាក្យស្នើសុំទូទាត់និងឯកសារពាក់ព័ន្ធ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ
- អាជ្ញាបណ្ណប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- លក្ខន្តិកៈក្រុមហ៊ុន និងបទពិសោធន៍ការងារ
- សេចក្តីព្រាងនៃផែនការអនុវត្តគម្រោង "**ស.ផ.គ.**" (Project Proposal Plan-PPP) ដោយត្រូវបំពេញឯកសារដូចខាងក្រោម៖
    - ផែនការបច្ចេកទេសសង្ខេបដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៣(ក) នៃសេចក្តីណែនាំនេះ និង
    - ផែនការហិរញ្ញវត្ថុសង្ខេបដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៤(ក) នៃសេចក្តីណែនាំនេះ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដូចបានកំណត់ក្នុងខ្លឹមសារ និងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

**ខ) ចំពោះការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៧ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨ ឬគម្រោងដែលបានសម្រេចក្នុងឆ្នាំ២០១៨ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៩៖**

- ពាក្យស្នើសុំទូទាត់និងឯកសារពាក់ព័ន្ធ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំនេះ
- អាជ្ញាបណ្ណប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍
- លក្ខន្តិកៈក្រុមហ៊ុន និងបទពិសោធន៍ការងារ
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចដោយសវនករឯករាជ្យ
- សេចក្តីព្រាងនៃផែនការអនុវត្តគម្រោង "**ស.ផ.គ.**" (Project Proposal Plan-PPP) ដោយត្រូវបំពេញឯកសារដូចខាងក្រោម៖
    - ផែនការបច្ចេកទេសសង្ខេបដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៣(ក) នៃសេចក្តីណែនាំនេះ និង
    - ផែនការហិរញ្ញវត្ថុសង្ខេបដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៤(ក) នៃសេចក្តីណែនាំនេះ
- ឯកសារពាក់ព័ន្ធផ្សេងទៀតដូចបានកំណត់ក្នុងខ្លឹមសារ និងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ។

## ៣. នីតិវិធីនៃការស្នើសុំទូទាត់ និងការសម្រេចលើការស្នើសុំទូទាត់

ប្រតិបត្តិករទូរគមនាគមន៍ ដែលមានគម្រោងស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវគោរពតាមនីតិវិធីនិងពេលវេលាកំណត់ ដូចខាងក្រោម៖

**៣.១. នីតិវិធីនិងកាលបរិច្ឆេទសំខាន់ៗពាក់ព័ន្ធការស្នើសុំទូទាត់ ត្រូវបានកំណត់ដូចខាងក្រោម៖**

| ដំណាក់កាល | ដំណើរការ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ដាក់ឯកសារបន្ថែមពាក់ព័ន្ធ(បឋម)នឹងការស្នើសុំការទូទាត់រវាងមូលនិធិ **ក.ស.ទ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** | -សម្រាប់ឆ្នាំ២០១៧៖ យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨<br>-សម្រាប់ឆ្នាំ២០១៨៖ យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៩ |
| ២ | ការពិនិត្យ ការវាយតម្លៃ និងរៀបចំរបាយការណ៍លើការទូទាត់រវាងមូលនិធិ **ក.ស.ទ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** ដោយលេខាធិការដ្ឋាន | យ៉ាងយូរ ៦០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារ |
| ៣ | ការពិនិត្យនិងការសម្រេចលើការទូទាត់រវាងមូលនិធិ **ក.ស.ទ.** ជាមួយនឹងគម្រោងអនុវត្តកម្មវិធី **ក.ស.ទ.** ដោយ ក.ម.ក.ស.ទ. | យ៉ាងយូរ ២០ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបញ្ចប់ការពិនិត្យ ការវាយតម្លៃ និងរៀបចំរបាយការណ៍លើការទូទាត់រវាង មូលនិធិ **ក.ស.ទ.** ជាមួយគម្រោង អនុវត្តកម្មវិធី **ក.ស.ទ.** ដោយលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. |
| ៤ | ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការសម្រេចផ្តល់ការទូទាត់ ត្រូវផ្តល់នូវឯកសារបន្ថែម (ពេញលេញ) ពាក់ព័ន្ធនឹងការទូទាត់ មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. | យ៉ាងយូរ ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលទទួលបានសេចក្តីសម្រេចស្តីពីការផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយគម្រោងអនុវត្តកម្មវិធី ក.ស.ទ. |

### ៣.២. នីតិវិធីនៃការស្នើសុំទូទាត់

ប្រតិបត្តិករទូរគមនាគមន៍ ដែលមានគម្រោងស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវដាក់ឯកសារពាក់ព័ន្ធនឹងការស្នើសុំដូចមានកំណត់ក្នុងចំណុច ២.២. (បែបបទនៃការស្នើសុំទូទាត់) នៃសេចក្តីណែនាំនេះ មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. តាមកាលបរិច្ឆេទកំណត់ដូចខាងក្រោម៖

ក) **យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨៖** ចំពោះការស្នើសុំទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ឬ/និងការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៧ ឬកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨។

ខ) **យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩៖** ចំពោះការស្នើសុំទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ឬ/និងការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៨ ឬកំពុងអនុវត្តបន្តក្នុងឆ្នាំ២០១៩។

### ៣.៣. នីតិវិធីនៃការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍អំពីការស្នើសុំទូទាត់

ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវត្រួតពិនិត្យ និងវាយតម្លៃលើឯកសារស្នើសុំទូទាត់ដែលបានដាក់មកដោយប្រតិបត្តិករទូរគមនាគមន៍ និងរៀបចំរបាយការណ៍ស្តីពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។ ក្នុងករណីដែលទិន្នន័យទទួលបានពីប្រតិបត្តិករទូរគមនាគមន៍និងទិន្នន័យដែលចុះពិនិត្យ សិក្សា វិភាគ និងវាយតម្លៃដោយលេខាធិការដ្ឋាននៃ

ក.ម.ក.ស.ទ. មានសង្គតិភាពនឹងគ្នា លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដើម្បីរៀបចំជារបាយការណ៍ស្តីពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដាក់ជូន ក.ម.ក.ស.ទ. ពិនិត្យនិងសម្រេច។ លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. អាចស្នើសុំឯកសារបន្ថែម ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ដែលដាក់ពាក្យស្នើសុំទូទាត់ បានដាក់ឯកសារមិនទាន់គ្រប់គ្រាន់។

ក្នុងករណីដែលទិន្នន័យទទួលបានពីប្រតិបត្តិករទូរគមនាគមន៍និងទិន្នន័យដែលចុះពិនិត្យ សិក្សា វិភាគ និងវាយតម្លៃដោយលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. មិនមានសង្គតិភាពនឹងគ្នា លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. និងប្រតិបត្តិករទូរគមនាគមន៍ដែលបានស្នើសុំទូទាត់ ត្រូវចុះទៅពិនិត្យទីតាំងដោយផ្ទាល់រួមគ្នា ដើម្បីបញ្ជាក់អំពីព័ត៌មាននិងទិន្នន័យជាក់ស្តែងម្តងទៀត។ បន្ទាប់ពីមានការឯកភាពគ្នាលើទិន្នន័យរួចហើយ លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវពិនិត្យមើលរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដើម្បីរៀបចំជារបាយការណ៍ស្តីពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដាក់ជូន ក.ម.ក.ស.ទ. ពិនិត្យនិងសម្រេច។

### ៣.៤. នីតិវិធីនៃការពិនិត្យនិងការសម្រេចលើការស្នើសុំទូទាត់

ក្នុងរយៈពេលយ៉ាងយូរ ២០(ម្ភៃ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីលេខាធិការដ្ឋាននៃក.ម.ក.ស.ទ. បានបញ្ជូនរបាយការណ៍ ដូចមានកំណត់ក្នុងចំណុច ៣.៣. (នីតិវិធីនៃការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀបចំរបាយការណ៍អំពីការស្នើសុំទូទាត់) ខាងលើ ក.ម.ក.ស.ទ. នឹងបើកកិច្ចប្រជុំដើម្បីធ្វើការពិនិត្យនិងសម្រេចលើការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដោយពិនិត្យនិងពិចារណាលើចំណុចជាអាទិ៍ដូចខាងក្រោម៖

- ទីតាំងគម្រោងនៃការស្នើសុំទូទាត់
- ភាពត្រឹមត្រូវនិងច្បាស់លាស់នៃឯកសារគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធផ្សេងទៀត ដែលបានភ្ជាប់មកជាមួយនឹងពាក្យស្នើសុំទូទាត់
- លទ្ធភាពនិងសមត្ថភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករទូរគមនាគមន៍ដែលដាក់ពាក្យស្នើសុំទូទាត់ ក្នុងការអនុវត្ត ស.ផ.គ. របស់ខ្លួន និង
- ប្រវត្តិនិងបទពិសោធន៍របស់ប្រតិបត្តិករទូរគមនាគមន៍ដែលដាក់ពាក្យស្នើសុំទូទាត់ ពាក់ព័ន្ធនឹងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ បណ្តាញ ឬការផ្តល់សេវាទូរគមនាគមន៍។

ការសម្រេចផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ ក.ម.ក.ស.ទ. ដោយមានការបញ្ជាក់អំពីវិសាលភាពនៃគម្រោងនិងថវិកាដែលបានសម្រេច ផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

### ៣.៥. នីតិវិធីនៃការផ្តល់ឯកសារបន្ថែមពាក់ព័ន្ធនឹងការទូទាត់

ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលនូវសេចក្តីសម្រេចស្តីពីការផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្តល់មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. នូវឯកសារបន្ថែម ដូចខាងក្រោម៖

**ក) ចំពោះស្នើសុំទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.៖**

- ផែនការបច្ចេកទេសលម្អិតដូចមានកំណត់ឧបសម្ព័ន្ធទី៣(ខ) នៃសេចក្តីណែនាំនេះ
- ផែនការហិរញ្ញវត្ថុលម្អិតដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤(ខ) និងឧបសម្ព័ន្ធទី៥ នៃសេចក្តីណែនាំ

នេះ។ ក្នុងករណីមានតម្រូវការចាំបាច់ក្នុងការបន្ថែមថវិកា ដើម្បីអនុវត្តគម្រោងដែលបានអនុម័តរួច ដោយ ក.ម.ក.ស.ទ. ថវិកាបន្ថែមមិនត្រូវមានចំនួនលើសពី ១០%(ដប់ភាគរយ) នៃថវិកាដែលបានអនុម័តដោយ ក.ម.ក.ស.ទ. ឡើយ។ ការបន្ថែមថវិកានេះ ត្រូវសម្រេចដោយ ក.ម.ក.ស.ទ.។

- កាលវិភាគនៃការអនុវត្តគម្រោង ដែលត្រូវរៀបចំដោយប្រតិបត្តិករទូរគមនាគមន៍ផ្ទាល់ ដោយពេលវេលាសរុបសម្រាប់អនុវត្តគម្រោងទាំងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងទាំងគម្រោងនៃការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវាបញ្ចូលគ្នាមិនត្រូវលើសពី ០៨ (ប្រាំបី) ខែ ដោយគិតពីថ្ងៃដែល ក.ម.ក.ស.ទ. បានសម្រេចផ្តល់ការទូទាត់។ ក្នុងនោះ ពេលវេលាអតិបរមាសម្រាប់អនុវត្តគម្រោងនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ មានរយៈពេលមិនលើសពី០៥ (ប្រាំ) ខែ និងពេលវេលាអតិបរមាសម្រាប់អនុវត្តគម្រោងនៃការរៀបចំឡើងវិញ ឬការដំឡើងនូវហេដ្ឋារចនា-សម្ព័ន្ធផ្តល់សេវា មានរយៈពេលមិនលើសពី០៣(បី)ខែ។
- ផែនការថែទាំ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៦ នៃសេចក្តីណែនាំនេះ។

**ខ) ចំពោះការស្នើសុំទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៧ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨ ឬគម្រោងដែលបានសម្រេចក្នុងឆ្នាំ ២០១៨ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៩៖**

- ផែនការបច្ចេកទេសលម្អិតដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៣(ខ) នៃសេចក្តីណែនាំនេះ
- ផែនការហិរញ្ញវត្ថុលម្អិតដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៤(ខ) និងឧបសម្ព័ន្ធទី៥ នៃសេចក្តីណែនាំនេះ
- ឯកសារហិរញ្ញវត្ថុផ្សេងទៀតតាមការកំណត់របស់ ក.ម.ក.ស.ទ. និងលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ.។

## ៤. វិធាននៃការទូទាត់

### ៤.១. ការទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.

ដើម្បីធ្វើការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែល ក.ម.ក.ស.ទ. បានអនុម័តរួច ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការសម្រេចទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវដាក់មកនូវរបាយការណ៍ស្តីពីវឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធ ជូនលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ព្រមទាំងចូលរួមសហការជាមួយលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ក្នុងការពិនិត្យ ការវាយតម្លៃ និងការផ្ទៀងផ្ទាត់ទំហំការងារដែលសម្រេចបាន។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរៀបចំការទូទាត់ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ ការវាយតម្លៃ និងការផ្ទៀតផ្ទាត់លើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ ឯកសារហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោង និងការងារដែលសម្រេចបានជាក់ស្តែង ដោយត្រូវធ្វើការទូទាត់តាម ០៣ (បី)ដំណាក់កាល ដូចខាងក្រោម៖

**ក) ដំណាក់កាលទី១៖** នៅពេលដែលលទ្ធផលនៃគម្រោងសម្រេចបាន ៣០% (សាមសិបភាគរយ) ត្រូវផ្តល់ការទូទាត់នូវទឹកប្រាក់ចំនួន ៣០% (សាមសិបភាគរយ) នៃថវិកាសរុបនៃគម្រោងដែលបានអនុម័ត

**ខ) ដំណាក់កាលទី២៖** នៅពេលដែលលទ្ធផលនៃគម្រោងសម្រេចបាន ៦០% (ហុកសិបភាគរយ) ត្រូវផ្តល់ការទូទាត់នូវទឹកប្រាក់បន្ថែមចំនួន ៣០% (សាមសិបភាគរយ) នៃថវិកា

សរុបនៃគម្រោងដែលបានអនុម័ត

**គ)ដំណាក់កាលទី៣៖** នៅពេលដែលលទ្ធផលនៃគម្រោងសម្រេចបាន ១០០% (មួយរយភាគរយ) ត្រូវផ្តល់ការទូទាត់នូវចំនួនទឹកប្រាក់ដែលនៅសល់នៃថវិកាសរុបនៃគម្រោងដែលបានអនុម័ត។

ក្នុងករណីចាំបាច់ លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. អាចពិនិត្យនិងពិចារណាផ្តល់បុរេប្រទានក្នុងចំនួនទឹកប្រាក់មិនលើសពី ១០% (ដប់ភាគរយ) នៃថវិកាសរុបនៃគម្រោងដែលបានអនុម័តរួច តាមការស្នើសុំរបស់ប្រតិបត្តិករទូរគមនាគមន៍ និងនៅពេលដែលប្រតិបត្តិករទូរគមនាគមន៍បានដឹកជញ្ជូនសម្ភារៈបរិក្ខារសម្រាប់សាងសង់ទៅដល់ ទីកន្លែងសាងសង់។ ក្នុងករណីនេះ ការទូទាត់ក្នុងដំណាក់កាលទី១ ត្រូវផ្តល់ក្នុងចំនួនទឹកប្រាក់ ២០% (ម្ភៃភាគរយ) នៃថវិកាសរុបនៃគម្រោងដែលបានអនុម័តរួច។

**៤.២. ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចក្នុងឆ្នាំ២០១៧ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨ ឬគម្រោងដែលបានសម្រេចក្នុងឆ្នាំ២០១៨ និងកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៩**

**ក) ចំពោះគម្រោងដែលបានសម្រេចក្នុងឆ្នាំ២០១៧ ឬឆ្នាំ២០១៨**

ដើម្បីធ្វើការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានសម្រេចរួចក្នុងឆ្នាំ២០១៧ ឬឆ្នាំ២០១៨ ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការសម្រេចទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវជូនរបាយការណ៍ស្តីពីវឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធ មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ព្រមទាំងចូលរួមសហការជាមួយលេខាធិការដ្ឋានក្នុងការពិនិត្យ ការវាយតម្លៃ និងការផ្ទៀងផ្ទាត់លទ្ធផលការងារដែលសម្រេចបាន។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរៀបចំការទូទាត់ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ ការវាយតម្លៃ និងការផ្ទៀតផ្ទាត់លើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ ឯកសារហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការចំណាយក្នុងការអនុវត្តគម្រោង និងលទ្ធផលការងារដែលសម្រេចបានទាំងស្រុងក្នុងឆ្នាំ២០១៧ ឬឆ្នាំ២០១៨ នូវចំនួនទឹកប្រាក់ ១០០% (មួយរយភាគរយ) នៃថវិកាសរុបនៃគម្រោងដែលបានអនុម័ត។

**ខ) ចំពោះគម្រោងដែលកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨ ឬឆ្នាំ២០១៩**

គម្រោងដែលកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៨ គឺសំដៅលើគម្រោងដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៧ ហើយបានអនុវត្តបញ្ចប់ឬកំពុងអនុវត្តបន្តក្នុងឆ្នាំ២០១៨។

គម្រោងដែលកំពុងដំណើរការបន្តក្នុងឆ្នាំ២០១៩ គឺសំដៅលើគម្រោងដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៨ ហើយបានអនុវត្តបញ្ចប់ឬកំពុងអនុវត្តបន្តក្នុងឆ្នាំ២០១៩។

ដើម្បីធ្វើការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៧ ហើយបានអនុវត្តបញ្ចប់ឬកំពុងអនុវត្តបន្តក្នុងឆ្នាំ២០១៨ ឬគម្រោងដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៨ ហើយបានអនុវត្តបញ្ចប់ឬកំពុងអនុវត្តបន្តក្នុងឆ្នាំ២០១៩ ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការសម្រេចផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវដាក់មកនូវរបាយការណ៍ស្តីពីវឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធ ជូនលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ព្រមទាំងចូលរួមសហការជាមួយលេខាធិការដ្ឋានក្នុងការពិនិត្យ ការវាយតម្លៃ និងការផ្ទៀងផ្ទាត់លទ្ធផលការងារដែលសម្រេចបាន។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរៀបចំការទូទាត់ដោយផ្អែកលើលទ្ធផលនៃការពិនិត្យ ការវាយតម្លៃ និងការផ្ទៀងផ្ទាត់លើរបាយការណ៍ស្តីពីវឌ្ឍនភាពការងារ ឯកសារហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការចំណាយក្នុងការអនុវត្តគម្រោង និងលទ្ធផលការងារដែលសម្រេចបាន ដូចខាងក្រោម៖

- ចំពោះគម្រោងដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៧ ហើយបានអនុវត្តបញ្ចប់ទាំងស្រុងក្នុងឆ្នាំ ២០១៨ ឬគម្រោងដែលចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៨ ហើយបានបញ្ចប់ទាំងស្រុងក្នុងឆ្នាំ ២០១៩ ការទូទាត់ត្រូវផ្តល់ក្នុងចំនួនទឹកប្រាក់ ១០០% (មួយរយភាគរយ) នៃថវិកាសរុបនៃគម្រោងដែលបានអនុម័ត
- ចំពោះគម្រោងដែលបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០១៧ឬឆ្នាំ២០១៨ ហើយកំពុងអនុវត្តបន្តក្នុងឆ្នាំ ២០១៨ឬឆ្នាំ២០១៩ ការទូទាត់ត្រូវផ្តល់ក្នុងចំនួនទឹកប្រាក់តាមដំណាក់កាល ដូចបានកំណត់ក្នុងចំណុច ៤.១. (ការទូទាត់ជាមុនរវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.) នៃសេចក្តីណែនាំនេះ។

### ៤.៣. គម្រោងដែលមិនអាចធ្វើការទូទាត់បាន

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. មិនត្រូវធ្វើការទូទាត់ចំពោះគម្រោងទាំងឡាយណាដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

ក) ជាគម្រោងដែលមិនឆ្លើយតបទៅនឹងផែនការបច្ចេកទេសនិងផែនការហិរញ្ញវត្ថុដែលបានដាក់ជូន ក.ម.ក.ស.ទ.

ខ) ជាគម្រោងដែលបានបញ្ចប់នៅមុនឆ្នាំ២០១៧

គ) ជាគម្រោងនៃការរៀបចំកម្មវិធីសម្ពោធដាក់ឱ្យដំណើរការគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ឬកម្មវិធីឬព្រឹត្តិការណ៍ផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា ដូចមានកំណត់ក្នុងចំណុច ១.១. (គម្រោងនិងវិសាលភាពការងារដែលអនុញ្ញាតឱ្យមានការស្នើសុំទូទាត់) នៃសេចក្តីណែនាំនេះ។

ឃ. ជាគម្រោងដែលបាននិងកំពុងស្ថាបនាក្រោមជំនួយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬជំនួយរបស់បរទេស ឬជំនួយរបស់ដៃគូអភិវឌ្ឍន៍ ជាអាទិ៍។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍អំពីគម្រោងដែលមិនអាចធ្វើការទូទាត់បានមក ក.ម.ក.ស.ទ. ដើម្បីពិនិត្យនិងសម្រេចលុបចោលការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដែលមានលក្ខណៈសម្បត្តិខាងលើ។

## ៥. ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃ

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវធ្វើការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃចំពោះគម្រោងដែលទទួលបានការអនុម័តផ្តល់ការទូទាត់ដោយ ក.ម.ក.ស.ទ. តាមរយៈសេចក្តីសម្រេចផ្តល់ការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវធ្វើការរាយការណ៍ជាប្រចាំជូន ក.ម.ក.ស.ទ. នូវលទ្ធផលនៃការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើដំណើរការនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា និងការគ្រប់គ្រងនិងការប្រើប្រាស់ផលនៃគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធផ្សេងទៀតជាប្រចាំ ឬតាមការស្នើសុំរបស់លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ។ របាយការណ៍ស្តីពីវឌ្ឍនភាពការងារនិងឯកសារពាក់ព័ន្ធនេះ ត្រូវផ្តល់មកជាឯកសារក្នុងទម្រង់ជាក្រដាស់ (Hard copy) ដែលបានដាក់ចំណងជើង កាលបរិច្ឆេទ និងមានការចុះហត្ថលេខារបស់អ្នកទទួលខុសនិងបានប្រថាប់ត្រារបស់ប្រតិបត្តិករទូរគមនាគមន៍ឱ្យបានច្បាស់លាស់ និងជាឯកសារក្នុងទម្រង់ជាឌីជីថល (Soft copy) ដោយមានចំណងជើងនិងកាលបរិច្ឆេទច្បាស់លាស់។ ឯកសារក្នុងទម្រង់ទាំង០២(ពីរ)នេះ ត្រូវមានព័ត៌មាននិងទិន្នន័យដូចគ្នា។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរៀបចំរបាយការណ៍ជូន ក.ម.ក.ស.ទ ដើម្បីពិនិត្យនិងសម្រេចជាផ្លូវការអំពីការបញ្ចប់ជាស្ថាពរដោយជោគជ័យនៃគម្រោងដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដោយពិចារណាលើចំណុចជាអាទិ៍ ដូចខាងក្រោម៖

- វិសាលភាពការងារត្រូវបានអនុវត្ត ១០០% (មួយរយភាគរយ) និងបណ្តាឧបករណ៍ទូរគមនាគមន៍ និងឧបករណ៍ពាក់ព័ន្ធទាំងអស់សម្រាប់ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការ ដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា មានដំណើរការតាមលក្ខណៈបច្ចេកទេសសមស្របដែលបានពិនិត្យ និងបញ្ជាក់ដោយលេខាធិការដ្ឋាន
- លិខិតស្នើសុំបញ្ចប់គម្រោងរបស់ប្រតិបត្តិករទូរគមនាគមន៍ ដោយបានភ្ជាប់មកជាមួយនឹងរបាយការណ៍លម្អិតចុងក្រោយ ការបូកសរុបការងារដែលបានអនុវត្តកន្លងមកនិងការបញ្ជាក់អំពីវិសាលភាពការងារដែលត្រូវបានអនុវត្ត ១០០% និងបណ្តាឧបករណ៍ទូរគមនាគមន៍និងឧបករណ៍ពាក់ព័ន្ធសម្រាប់ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវាមានដំណើរការតាមលក្ខណៈបច្ចេកទេសសមស្រប។

ការទទួលស្គាល់អំពីការបញ្ចប់ជាស្ថាពរដោយជោគជ័យនៃគម្រោង ដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ត្រូវធ្វើឡើងតាមរយៈសេចក្តីសម្រេចរបស់ ក.ម.ក.ស.ទ. ដោយបញ្ជាក់ផងដែរនូវសិទ្ធិនៃការគ្រប់គ្រងនិងការប្រើប្រាស់ផលនៃគម្រោងដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

## ៦. ការស្នើសុំពន្យាពេលអនុវត្តគម្រោង និងករណីយឺតយ៉ាវ

ក្នុងករណីចាំបាច់ ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបាននូវការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ពី ក.ម.ក.ស.ទ. អាចធ្វើការស្នើសុំពន្យាពេលអនុវត្តគម្រោងនៃការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋារចនាសម្ព័ន្ធផ្តល់សេវា ជាលាយលក្ខណ៍អក្សរមកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ដោយភ្ជាប់មកនូវមូលហេតុច្បាស់លាស់។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. អាចធ្វើការសម្រេចអនុញ្ញាតពន្យាពេលអនុវត្តគម្រោងក្នុងរយៈពេលសរុបមិនលើសពីពាក់កណ្តាលនៃរយៈពេលសរុបនៃការអនុវត្តគម្រោង ជូនប្រតិបត្តិករទូរគមនាគមន៍ដែលបានស្នើសុំពន្យាពេល ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- ដោយសារមានករណីប្រធានសក្តិ
- ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់ បានខិតខំអស់ពីលទ្ធភាពក្នុងអនុវត្តនិងបានចាត់វិធានការសមស្របដើម្បីជៀសវាងការពន្យាពេលឬកាត់បន្ថយការពន្យាពេល និងបានចាត់

វិធានការសមស្របដើម្បីបន្តការងារ

- ការពន្យាពេលមិនមែនកើតឡើងពីការធ្វេសប្រហែស ឬការមិនអនុវត្តឱ្យបានពេញលេញនិងត្រឹមត្រូវរបស់ប្រតិបត្តិករទូរគមនាគមន៍ តាមការកំណត់ក្នុងសេចក្តីណែនាំនេះនិងបទប្បញ្ញត្តិផ្សេងទៀត។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. មិនត្រូវអនុញ្ញាតឱ្យមានការពន្យាពេលក្នុងការអនុវត្តគម្រោងដល់ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់ ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

- មិនមានភាពចាំបាច់ក្នុងការពន្យាពេលអនុវត្តគម្រោង
- គោលបំណងនៃការពន្យាពេលអនុវត្តគម្រោងរបស់ប្រតិបត្តិករទូរគមនាគមន៍ ធ្វើឡើងដើម្បីធ្វើឱ្យគម្រោងបរាជ័យ ( Default or Bankrupt )
- ការពន្យាពេលអនុវត្តគម្រោងនាំឱ្យការអនុវត្តគម្រោងត្រូវបរាជ័យ ឬមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ផ្នែកផ្សេងទៀតនៃគម្រោង។

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍ជូន ក.ម.ក.ស.ទ. អំពីការសម្រេចខាងលើ។ លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍ជូន ក.ម.ក.ស.ទ. ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍មិនអនុវត្តតាមការសម្រេចនេះ ដើម្បីឱ្យ ក.ម.ក.ស.ទ. ពិនិត្យនិងសម្រេចដកហូតសិទ្ធិក្នុងការអនុវត្តគម្រោងដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. និងអាចប្រគល់នូវគម្រោងនេះទៅឱ្យប្រតិបត្តិករទូរគមនាគមន៍ផ្សេងទៀត ព្រមទាំងកំណត់នូវសំណងតាមទំហំនៃព្យសនកម្មដែលបានកើតឡើង។

ត្រូវចាត់ទុកជាការយឺតយ៉ាវក្នុងការអនុវត្តគម្រោងដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. នៅក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់ មិនបានបញ្ចប់គម្រោងក្នុងរយៈពេលយ៉ាងយូរ ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទបញ្ចប់គម្រោងដូចមានកំណត់ក្នុងកាលវិភាគនៃការអនុវត្តគម្រោងដែលបានផ្តល់មកលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. និងមិនមានការអនុញ្ញាត ពន្យាពេលពីលេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ.។

ក្នុងករណីដែលប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់យឺតយ៉ាវក្នុងការអនុវត្តគម្រោងលើសពី ០១(មួយ)ខែ ដោយពុំមានការអនុញ្ញាតពន្យាពេល លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវរាយការណ៍ភ្លាមទៅ ក.ម.ក.ស.ទ. ដើម្បីពិនិត្យនិងសម្រេចដកហូតសិទ្ធិក្នុងការអនុវត្តគម្រោងដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. និងអាចប្រគល់នូវគម្រោងនេះទៅឱ្យប្រតិបត្តិករទូរគមនាគមន៍ផ្សេងទៀត ព្រមទាំងកំណត់នូវសំណងតាមទំហំនៃព្យសនកម្មដែលបានកើតឡើង។

## ៧. ការធានាចំពោះការអនុវត្តគម្រោងដែលទទួលបានការទូទាត់

### ៧.១. ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

ប្រតិបត្តិករទូរគមនាគមន៍ដែលទទួលបានការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ពី ក.ម.ក.ស.ទ. ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច លើការងារដូចខាងក្រោម៖

- ស្នើសុំការអនុញ្ញាតពីរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ច មុននឹងចាប់ផ្តើមអនុវត្តការងារស្ថាបនាហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការរៀបចំឡើងវិញឬការដំឡើងនូវហេដ្ឋា-រចនាសម្ព័ន្ធផ្តល់សេវា

ជាធរមាន

- អនុវត្តឱ្យបានត្រឹមត្រូវនូវកិច្ចការពារអ្នកប្រើប្រាស់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ធ្វើឱ្យមានសង្គតិភាពជាមួយស្តង់ដាគុណភាពនៃសេវាទូរគមនាគមន៍ ទោះបីជាមានករណីតម្រូវឱ្យមានការកាត់បន្ថយវិសាលភាពគ្របដណ្តប់និងកម្លាំងនៃការផ្សាយ ដោយមូលហេតុដោយថាហេតុណាមួយរបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៨.៣. ការតាមដានការអនុវត្តរបស់ប្រតិបត្តិករទូរគមនាគមន៍ ដែលទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលនៃគម្រោងដែលទទួលពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.**

លេខាធិការដ្ឋាននៃ ក.ម.ក.ស.ទ. ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកាតព្វកិច្ចទាំងអស់របស់ប្រតិបត្តិករទូរគមនាគមន៍ ដែលទទួលបានសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលនៃគម្រោងដែលទទួលបានពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ដូចខាងក្រោម៖

ក. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើឯកសារ និងចុះទៅដល់ទីតាំងនៃគម្រោងដើម្បីបញ្ជាក់អំពីការអនុវត្តរបស់ប្រតិបត្តិករទូរគមនាគមន៍ ដែលទទួលសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលនៃគម្រោងដែលទទួលបានពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ. ពិតជាគោរពតាមកាតព្វកិច្ចនៃការផ្តល់សេវាទូរគមនាគមន៍ ជាអាទិ៍ ទីតាំង គុណភាព បរិមាណ ពេលវេលា តម្លៃសេវា និងលក្ខណៈបច្ចេកទេសដែលបានកំណត់ក្នុងសេចក្តីណែនាំនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្នែកហិរញ្ញវត្ថុតាមរយៈការផ្ទៀងផ្ទាត់រាល់ឯកសារហិរញ្ញវត្ថុនិងឯកសារពាក់ព័ន្ធ ដែលផ្តល់ឱ្យដោយប្រតិបត្តិករទូរគមនាគមន៍ទទួលសិទ្ធិគ្រប់គ្រងនិងប្រើប្រាស់ផលនៃគម្រោងដែលទទួលបានពីការទូទាត់រវាងមូលនិធិ ក.ស.ទ. ជាមួយនឹងគម្រោងអនុវត្តកម្មវិធី ក.ស.ទ.។

ទទួលបានសេចក្តីណែនាំនេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ និងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ច័ន្ទ ៥រោច ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ ខែ សីហា ឆ្នាំ២០១៨

**ជ. ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ច**

**សេវាសកលទូរគមនាគមន៍**

**ប្រធាន**

**ស្រី អ៊ិនតិក**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ឯកសារ-កាលប្បវត្តិ